**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មការមូលបត្រកម្ពុជា**

លេខ:.........០០៣/១៥.........គ.ម.ក/ប្រ.ក.

# ប្រកាស
# ស្តីពី
# លក្ខខណ្ឌតម្រូវលើភាពរឹងមាំហិរញ្ញវត្ថុនៃក្រុមហ៊ុនមូលបត្រ

* * * * *

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## និងជាប្រធាននៃគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០២/០១១ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និង វិជ្ជាជីវៈគណនេយ្យ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួយដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញប្រកាសលេខ ០០៩ គមក ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្តីពីការផ្តល់អាជ្ញាបណ្ណដល់ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រ

អាសយដ្ឋានបណ្តោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា
Temporary Address: #99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia. www.secc.gov.kh
ទូរស័ព្ទ: ៨៥៥-២៣-៨៨៥-៦១១
Phone : 855-23-885-611
E-mail : info@secc.gov.kh
ទូរសារ: ៨៥៥-២៣-៨៨៥-៦២២
Fax : 855-23-885-622

- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជានាថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១២

**ស ម្រេ ច**

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-គោលបំណង**

ប្រកាសនេះមានគោលដៅចែងពីបទប្បញ្ញត្តិដើម្បីត្រួតពិនិត្យលើភាពរឹងមាំផ្នែកហិរញ្ញវត្ថុនៃក្រុមហ៊ុនមូលបត្រដែលធ្វើអាជីវកម្មជាក្រុមហ៊ុនធានាទិញមូលបត្រ ពាណិជ្ជករមូលបត្រ និងឈ្មួញជើងសាមូលបត្រ ដោយអនុលោមតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ។

**ប្រការ ២.-និយមន័យ**

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់នៅក្នុងប្រកាសនេះ ត្រូវបានកំណត់ក្នុងប្រការនេះ និងមាននៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការជួញដូរមូលបត្រមហាជន÷

កម្រិតមូលធនសុទ្ធកាតព្វកិច្ច (Prescribed Level of Net Capital): សំដៅដល់កម្រិតអប្បបរមានៃមូលធនសុទ្ធដែលក្រុមហ៊ុនមូលបត្រត្រូវរក្សាឱ្យបានគ្រប់ពេលវេលា ដូចមានកំណត់នៅក្នុងប្រការ ១៧ នៃប្រកាសនេះ។

ការតម្រូវពង្រឹងការគ្រប់គ្រង (Management Improvement Requirement): សំដៅដល់ការតម្រូវឱ្យក្រុមហ៊ុនមូលបត្រពង្រឹងការគ្រប់គ្រងនៅពេលអនុបាតមូលធនសុទ្ធរបស់ក្រុមហ៊ុននោះធ្លាក់ក្រោម ១២០ (មួយរយម្ភៃ) ភាគរយ ដូចមានចែងនៅក្នុងប្រការ ២៣ នៃប្រកាសនេះ។

ការបញ្ជាពង្រឹងការគ្រប់គ្រង (Management Improvement Order): សំដៅដល់ការបញ្ជាឱ្យក្រុមហ៊ុនមូលបត្រពង្រឹងការគ្រប់គ្រងនៅពេលអនុបាតមូលធនសុទ្ធរបស់ក្រុមហ៊ុននោះធ្លាក់ក្រោម ១០០ (មួយរយ) ភាគរយ ដូចមានចែងនៅក្នុងប្រការ ២៤ នៃប្រកាសនេះ។

ច្បាប់ (Law): សំដៅដល់ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

ប្រកាសផ្តល់អាជ្ញាបណ្ណក្រុមហ៊ុនមូលបត្រ (Prakas on Licensing of Securities Firm): សំដៅដល់ប្រកាសស្តីពីការផ្តល់អាជ្ញាបណ្ណដល់ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រ។

មូលធនភាគហ៊ុនិក (Shareholders' Equity): សំដៅដល់ទ្រព្យសកម្មដែលនៅសល់ចុងក្រោយបន្ទាប់ពីបានដកបំណុលទាំងអស់ចេញពីទ្រព្យសកម្មសរុបរបស់ក្រុមហ៊ុនមូលបត្រ ដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា។

លក្ខខណ្ឌចាប់បង្ខំសង្គម (Cross Default)៖ សំដៅដល់លក្ខខណ្ឌក្នុងកិច្ចសន្យាផ្តល់កម្ចីដែលការពារផលប្រយោជន៍ឥណទាយកដោយចែងពីករណីកូនបំណុលខកខានមិនបានបំពេញកាតព្វកិច្ចស្របតាមកិច្ចសន្យាផ្តល់កម្ចីណាមួយ ធ្វើឱ្យកើតឡើងនូវការខកខានមិនបានបំពេញកាតព្វកិច្ចសន្យាលើបំណុលផ្សេងទៀតដោយស្វ័យប្រវត្តិ។

លក្ខខណ្ឌហាមឃាត់ការខ្ចីប្រាក់បន្ថែម (Negative Pledge)៖ សំដៅដល់លក្ខខណ្ឌក្នុងកិច្ចសន្យាផ្តល់កម្ចីដែលហាមឃាត់កូនបំណុលមិនឱ្យខ្ចីបំណុលបន្ថែមដោយគ្មានការយល់ព្រមពីឥណទាយក។

អនុក្រឹត្យ (Sub-Decree)៖ សំដៅដល់អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការជួញដូរមូលបត្រមហាជន។

អនុបាតមូលធនសុទ្ធ (Net Capital Ratio)៖ សំដៅដល់ផលធៀបរវាងមូលធនសុទ្ធ និងមូលធនសុទ្ធកាតព្វកិច្ច។

អនុសាសន៍ពង្រឹងការគ្រប់គ្រង (Management Improvement Recommendation)៖ សំដៅដល់ការផ្តល់អនុសាសន៍ដល់ក្រុមហ៊ុនមូលបត្រឱ្យពង្រឹងការគ្រប់គ្រងនៅពេលអនុបាតមូលធនសុទ្ធរបស់ក្រុមហ៊ុននោះធ្លាក់ក្រោម ១៥០ (មួយរយហាសិប) ភាគរយ ដូចមានចែងនៅក្នុងប្រការ ២២ នៃប្រកាសនេះ។

ឥណទេយ្យមិនមែនពាណិជ្ជកម្ម (Non-Trading Receivable)៖ សំដៅដល់ទឹកប្រាក់ដទៃទៀតដែលអតិថិជនជំពាក់ក្រុមហ៊ុនមូលបត្រក្រៅពីឥណទេយ្យពាណិជ្ជកម្ម។

ឥណទេយ្យពាណិជ្ជកម្ម (Trading Receivable)៖ សំដៅដល់ទឹកប្រាក់ដែលអតិថិជនជំពាក់សម្រាប់ប្រតិបត្តិការបញ្ជាទិញរបស់អតិថិជនដែលរួមទាំងកម្រៃជើងសា។

## ជំពូកទី ២
## លក្ខខណ្ឌតម្រូវលើមូលធនភាគហ៊ុនិក

### ប្រការ ៣.-ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុ

ក្រុមហ៊ុនមូលបត្រ ត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយអនុលោមតាមច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ និងបទប្បញ្ញត្តិពាក់ព័ន្ធ និងត្រូវគណនាមូលធនសុទ្ធដោយអនុលោមតាមប្រកាសនេះ។

### ប្រការ ៤.-កាតព្វកិច្ចរក្សាមូលធនភាគហ៊ុនិក

ក្រុមហ៊ុនមូលបត្រ ត្រូវរក្សាមូលធនភាគហ៊ុនិកគ្រប់ពេលវេលាមិនឱ្យតិចជាងលក្ខខណ្ឌតម្រូវលើមូលធនអប្បបរមា ដែលបានកំណត់ក្នុងប្រកាសផ្តល់អាជ្ញាបណ្ណក្រុមហ៊ុនមូលបត្ររបស់គណៈកម្មការមូលបត្រកម្ពុជា (សរសេរកាត់ថា គ.ម.ក.) ទៅតាមប្រភេទអាជីវកម្មមូលបត្រដូចខាងក្រោម÷

១-ចំនួន ៤០.០០០.០០០.០០០ (សែសិបពាន់លាន) រៀល សម្រាប់ក្រុមហ៊ុនមូលបត្រដែលធ្វើអាជីវកម្មជាក្រុមហ៊ុនធានាទិញមូលបត្រ។

២-ចំនួន ២៥.០០០.០០០.០០០ (ម្ភៃប្រាំពាន់លាន) រៀល សម្រាប់ក្រុមហ៊ុនមូលបត្រដែលធ្វើអាជីវកម្មជាពាណិជ្ជករមូលបត្រ។

៣-ចំនួន ៦.០០០.០០០.០០០ (ប្រាំមួយពាន់លាន) រៀល សម្រាប់ក្រុមហ៊ុនមូលបត្រដែលធ្វើអាជីវកម្មជាឈ្មួញជើងសាមូលបត្រ។

ករណីក្រុមហ៊ុនមូលបត្រទទួលបានអាជ្ញាបណ្ណធ្វើអាជីវកម្មច្រើនជាងមួយនៃប្រភេទអាជីវកម្មមូលបត្រខាងលើ ក្រុមហ៊ុនមូលបត្រត្រូវបំពេញលក្ខខណ្ឌតម្រូវលើមូលធនអប្បបរមាដែលច្រើនជាងគេក្នុងកថាខណ្ឌទី ១ នៃប្រការនេះ សម្រាប់អាជីវកម្មមូលបត្រដែលកំណត់ក្នុងលក្ខខណ្ឌអាជ្ញាបណ្ណនីមួយៗ។

## ប្រការ ៥.-កាតព្វកិច្ចតម្កល់ប្រាក់ធានាអាជីវកម្ម និង/ឬឧបករណ៍តម្កល់ធានាអាជីវកម្ម

ក្រុមហ៊ុនមូលបត្រ ត្រូវរក្សាឱ្យបានគ្រប់ពេលនូវប្រាក់តម្កល់ធានាអាជីវកម្ម និង/ឬឧបករណ៍តម្កល់ធានាអាជីកម្មដែលកំណត់ក្នុងប្រកាសផ្តល់អាជ្ញាបណ្ណក្រុមហ៊ុនមូលបត្ររបស់ គ.ម.ក. ទៅតាមប្រភេទអាជីវកម្មនីមួយៗដូចខាងក្រោម÷

១-យ៉ាងតិចចំនួន ៤.០០០.០០០.០០០ (បួនពាន់លាន) រៀល សម្រាប់ក្រុមហ៊ុនមូលបត្រដែលធ្វើអាជីវកម្មជាក្រុមហ៊ុនធានាទិញមូលបត្រ។

២-យ៉ាងតិចចំនួន ២.៥០០.០០០.០០០ (ពីរពាន់ប្រាំរយលាន) រៀល សម្រាប់ក្រុមហ៊ុនមូលបត្រដែលធ្វើអាជីវកម្មជាពាណិជ្ជករមូលបត្រ។

៣-យ៉ាងតិចចំនួន ១.០០០.០០០.០០០ (មួយពាន់លាន) រៀល សម្រាប់ក្រុមហ៊ុនមូលបត្រដែលធ្វើអាជីវកម្មជាឈ្មួញជើងសាមូលបត្រ។

ករណីក្រុមហ៊ុនមូលបត្រដែលទទួលបានអាជ្ញាបណ្ណធ្វើអាជីវកម្មច្រើនជាងមួយនៃប្រភេទអាជីវកម្មមូលបត្រខាងលើ ក្រុមហ៊ុនមូលបត្រត្រូវបំពេញលក្ខខណ្ឌតម្រូវលើប្រាក់តម្កល់ធានាអាជីវកម្ម និង/ឬឧបករណ៍តម្កល់ធានាអាជីវកម្មដែលច្រើនជាងគេក្នុងកថាខណ្ឌទី ១ នៃប្រការនេះ សម្រាប់អាជីវកម្មមូលបត្រដែលកំណត់ក្នុងលក្ខខណ្ឌអាជ្ញាបណ្ណនីមួយៗ។

## ប្រការ ៦.-ការប្រើប្រាស់ប្រាក់តម្កល់ធានាអាជីវកម្ម និង/ឬឧបករណ៍តម្កល់ធានាអាជីវកម្ម

ក្រុមហ៊ុនមូលបត្រ មិនត្រូវប្រើប្រាស់ប្រាក់តម្កល់ធានាអាជីវកម្ម និង/ឬឧបករណ៍តម្កល់ធានាអាជីវកម្មដូចមានចែងក្នុងប្រការ ៥ នៃប្រកាសនេះ ធ្វើជាការធានាផ្សេងៗសម្រាប់ប្រើប្រាស់ក្នុងអាជីវកម្ម លើកលែងតែការដកសម្រាប់ប្រើប្រាស់ក្នុងគោលបំណងដូចមានកំណត់ក្នុងប្រកាសផ្តល់អាជ្ញាបណ្ណក្រុមហ៊ុនមូលបត្រ និងមានការអនុញ្ញាតពី គ.ម.ក. ។

## ប្រការ ៧.-កាតព្វកិច្ចជូនដំណឹង

ក្រុមហ៊ុនមូលបត្រ ត្រូវជូនដំណឹងភ្លាមដល់អគ្គនាយកនៃ គ.ម.ក. ក្នុងករណីក្រុមហ៊ុនមិនអាចបំពេញ ឬដឹងថាមិនអាចបំពេញកាតព្វកិច្ចនៅក្នុងប្រការ ៤ ប្រការ ៥ ឬប្រការ ៦ នៃប្រកាសនេះ។

# ជំពូកទី ៣
## លក្ខខណ្ឌតម្រូវលើមូលធនសុទ្ធ

### ប្រការ ៨.-កាតព្វកិច្ចរក្សាមូលធនសុទ្ធ

ដើម្បីធានាថាក្រុមហ៊ុនមូលបត្រមានលទ្ធភាពគ្រប់គ្រាន់ក្នុងការបំពេញកាតព្វកិច្ចហិរញ្ញវត្ថុរបស់ខ្លួន ក្រុមហ៊ុនមូលបត្រ ត្រូវគណនាមូលធនសុទ្ធដូចមានកំណត់ក្នុងប្រការ ៩ នៃប្រកាសនេះ និងត្រូវរក្សាមូលធនសុទ្ធរបស់ខ្លួនឱ្យបានគ្រប់ពេលវេលាមិនឱ្យទាបជាងកម្រិតមូលធនសុទ្ធកាតព្វកិច្ច និងគោរពតាមអនុបាតមូលធនសុទ្ធដូចមានកំណត់ក្នុងប្រការ ១៧ នៃប្រកាសនេះ។

ក្រុមហ៊ុនមូលបត្រ មិនត្រូវធ្វើប្រតិបត្តិការណាមួយដែលអាចបណ្តាលឱ្យក្រុមហ៊ុនមិនអាចបន្តបំពេញលក្ខខណ្ឌតម្រូវលើមូលធនសុទ្ធដែលចែងក្នុងកថាខណ្ឌទី ១ នៃប្រការនេះ។

ក្រុមហ៊ុនមូលបត្រ ត្រូវជូនដំណឹងភ្លាមដល់អគ្គនាយកនៃ គ.ម.ក. ក្នុងករណីក្រុមហ៊ុនមិនអាចបំពេញ ឬដឹងថាមិនអាចបំពេញកាតព្វកិច្ចក្នុងកថាខណ្ឌទី ១ នៃប្រការនេះ។

### ប្រការ ៩.-ការគណនាមូលធនសុទ្ធ

មូលធនសុទ្ធ ត្រូវគណនាដូចខាងក្រោម÷

មូលធនសុទ្ធ (Net Capital) = ទ្រព្យសកម្មរយៈពេលខ្លី (Current Assets) - បំណុលក្រៅសរុប (Total External Liabilities)

### ប្រការ ១០.-ទ្រព្យសកម្មរយៈពេលខ្លី

ទ្រព្យសកម្មរយៈពេលខ្លីស្របតាមប្រកាសនេះរួមមាន÷

១-សាច់ប្រាក់ និងទ្រព្យសកម្មទាំងអស់ស្របតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាដែលអាចបំលែងជាសាច់ប្រាក់បានក្នុងរយៈពេល ២ (ពីរ) សប្តាហ៍។

២-ប្រាក់តម្កល់ធានាអាជីវកម្ម និង/ឬឧបករណ៍តម្កល់ធានាអាជីវកម្មដូចមានកំណត់ក្នុងប្រកាសផ្តល់អាជ្ញាបណ្ណក្រុមហ៊ុនមូលបត្រ។

៣-មូលបត្រកាន់កាប់ដោយក្រុមហ៊ុនមូលបត្រដែលបានបំពេញលក្ខខណ្ឌនិងត្រូវបានវាយតម្លៃស្របតាមប្រការ ១១ នៃប្រកាសនេះ។

៤-ទ្រព្យសកម្មផ្សេងទៀតដែលកំណត់ដោយ គ.ម.ក.។

ទ្រព្យសកម្មដែលមិនត្រូវបានចាត់ចូលជាទ្រព្យសកម្មរយៈពេលខ្លីស្របតាមប្រកាសនេះរួមមាន÷

១-កម្ចីដែលផ្តល់ឱ្យ ឬគណនីឥណទេយ្យដែលនឹងទទួលពីភាគហ៊ុនិក ភ្នាក់ងារក្រុមហ៊ុនមូលបត្រ ភ្នាក់ងារផ្តល់ប្រឹក្សាវិនិយោគ បុគ្គលិកជាន់ខ្ពស់ និយោជិត និងបុគ្គលមានទំនាក់ទំនងពិសេសរបស់ពួកគេ និងបុគ្គលពាក់ព័ន្ធរបស់ក្រុមហ៊ុនមូលបត្រ។

២-ទ្រព្យអរូបិយ (Intangible Assets)។

៣-ចំណែកនៃបំណុលដែលអតិថិជនម្នាក់ជំពាក់លើសពី ១០ (ដប់) ភាគរយនៃទ្រព្យសកម្មរយៈពេលខ្លីសរុប។

៤-ឥណទេយ្យពាណិជ្ជកម្ម (Trading Receivable) ដែលមានរយៈពេលលើសពី ០៥ (ប្រាំ) ថ្ងៃនៃថ្ងៃជួញដូរ លើកលែងតែមានការអនុញ្ញាតផ្សេងពីនេះដោយ គ.ម.ក.។

៥-ឥណទេយ្យមិនមែនពាណិជ្ជកម្ម (Non-Trading Receivable) ដែលមានរយៈពេលលើសពី ៣(បី) ខែ។

៦-ទ្រព្យសកម្មផ្សេងទៀតដែលកំណត់ដោយ គ.ម.ក.។

## ប្រការ ១១.-ការរាប់បញ្ចូលមូលបត្រជាទ្រព្យសកម្មរយៈពេលខ្លី

ក្រុមហ៊ុនមូលបត្រអាចរាប់បញ្ចូលមូលបត្រដែលបានកាន់កាប់ជាទ្រព្យសកម្មរយៈពេលខ្លីបាន លុះត្រាតែមូលបត្រនោះ÷

១-ត្រូវបានជួញដូរដោយជោគជ័យក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃចុងក្រោយនៃថ្ងៃជួញដូរនៅក្នុងទីផ្សារមូលបត្រប្រតិស្រុតនៅព្រះរាជាណាចក្រកម្ពុជា។

២-ត្រូវបានវាយតម្លៃទៅតាមថ្លៃទីផ្សារបច្ចុប្បន្ន។

មូលបត្រកម្មសិទ្ធិដែលកាន់កាប់ដោយក្រុមហ៊ុនមូលបត្រដូចមានកំណត់ក្នុងកថាខណ្ឌទី ១ នៃប្រការនេះត្រូវវាយតម្លៃដូចខាងក្រោម÷

១-មូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុនដែលបានចុះបញ្ជីនៅទីផ្សារមូលបត្រប្រតិស្រុតនៅព្រះរាជាណាចក្រកម្ពុជាត្រូវវាយតម្លៃមិនលើសពី ៧០ (ចិតសិប) ភាគរយនៃថ្លៃទីផ្សាររបស់មូលបត្រកម្មសិទ្ធិនោះ។

២-មូលបត្រកម្មសិទ្ធិដែលបានចុះបញ្ជី ឬនឹងត្រូវចុះបញ្ជីនៅទីផ្សារមូលបត្រប្រតិស្រុតនៅព្រះរាជាណាចក្រកម្ពុជាដែលក្រុមហ៊ុនបានធ្វើបរិវិសកម្ម និង/ឬធានាទិញ និង/ឬធានាទិញបន្ត ត្រូវវាយតម្លៃមិនលើសពី ៧០ (ចិតសិប) ភាគរយនៃតម្លៃណាមួយដែលទាបជាងគេរវាងថ្លៃធ្វើបរិវិសកម្ម និងថ្លៃទីផ្សាររបស់មូលបត្រកម្មសិទ្ធិនោះ។

មូលបត្របំណុលដែលកាន់កាប់ដោយក្រុមហ៊ុនមូលបត្រដូចមានកំណត់ក្នុងកថាខណ្ឌទី ១ នៃប្រការនេះត្រូវវាយតម្លៃដូចខាងក្រោម÷

១-មូលបត្ររដ្ឋត្រូវវាយតម្លៃមិនលើសពី ៩០ (កៅសិប) ភាគរយនៃថ្លៃទីផ្សារ។

២-សញ្ញាបណ្ណដែលត្រូវបានចាត់ថ្នាក់ជាកម្រិតវិនិយោគ (Investment Grade Bond) និងសញ្ញាបណ្ណដែលធានាដោយរាជរដ្ឋាភិបាលកម្ពុជា ត្រូវវាយតម្លៃមិនលើសពី ៧០ (ចិតសិប) ភាគរយនៃថ្លៃទីផ្សាររបស់សញ្ញាបណ្ណនោះ។

៣-សញ្ញាបណ្ណសាជីវកម្មដែលបោះផ្សាយដទៃទៀតក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវវាយតម្លៃមិនលើសពី ៤០ (សែសិប) ភាគរយនៃថ្លៃទីផ្សាររបស់សញ្ញាបណ្ណនោះ។

៤-មូលបត្របំណុលដែលបានចុះបញ្ជី ឬនឹងត្រូវចុះបញ្ជីនៅទីផ្សារមូលបត្រប្រតិស្រុតនៅព្រះរាជាណាចក្រកម្ពុជាដែលក្រុមហ៊ុនបានធ្វើបរិវិសកម្ម និង/ឬធានាទិញ និង/ឬធានាទិញបន្ត ត្រូវវាយតម្លៃមិនលើសពី ៦០ (ហុកសិប) ភាគរយនៃតម្លៃណាមួយដែលទាបជាងគេរវាងថ្លៃធ្វើបរិវិសកម្ម និងថ្លៃទីផ្សាររបស់មូលបត្របំណុលនោះ។

**ប្រការ ១២.-ការកាត់បន្ថយលើទ្រព្យសកម្មរយៈពេលខ្លី**

ដើម្បីគណនាមូលធនសុទ្ធ ក្រុមហ៊ុនមូលបត្រត្រូវកាត់បន្ថយពីទ្រព្យសកម្មរយៈពេលខ្លីនូវធាតុមួយចំនួនដូចខាងក្រោម÷

១-សំវិធានធនសម្រាប់បំណុលអាក្រក់។ ក្រុមហ៊ុនមូលបត្រត្រូវផ្ដល់ជូន គ.ម.ក. នូវគោលនយោបាយផ្ទៃក្នុងទាក់ទងនឹងការគ្រប់គ្រងបំណុល និងការប៉ាន់ស្មានសំវិធានធនសម្រាប់បំណុលអាក្រក់។ អគ្គនាយកនៃ គ.ម.ក. អាចពិនិត្យឡើងវិញនូវគោលនយោបាយទាក់ទងនឹងការគ្រប់គ្រងបំណុលអាក្រក់ និងតម្រូវឱ្យក្រុមហ៊ុនមូលបត្របង្កើនកម្រិតសំវិធានធនសម្រាប់បំណុលអាក្រក់។

២-ធាតុផ្សេងទៀតដែលកំណត់ដោយអគ្គនាយកនៃ គ.ម.ក. ។

**ប្រការ ១៣.-ប្រតិបត្តិការមិនកត់ត្រា** (Off Record Transactions)

ក្រុមហ៊ុនមូលបត្រ ត្រូវបង្ហាញរាល់ប្រតិបត្តិការមិនកត់ត្រានៅក្នុងបញ្ជីគណនេយ្យដល់ គ.ម.ក.។ អគ្គនាយកនៃ គ.ម.ក. មានឆន្ទានុសិទ្ធិកំណត់កម្រិតនៃការកាត់បន្ថយលើទ្រព្យសកម្មរយៈពេលខ្លីក្នុងការគណនាមូលធនសុទ្ធសម្រាប់ប្រតិបត្តិការមិនកត់ត្រា។

**ប្រការ ១៤.-ឆន្ទានុសិទ្ធិកែប្រែកម្រិតកត្តាកាត់បន្ថយហានិភ័យ**

អគ្គនាយកនៃ គ.ម.ក. មានឆន្ទានុសិទ្ធិកែប្រែកម្រិតកត្តាកាត់បន្ថយហានិភ័យណាមួយដែលបានចែងក្នុងប្រការ ១១ និងប្រការ ១២ នៃប្រកាសនេះ ក្រោយពីវាយតម្លៃទៅតាមករណីនីមួយៗ។

**ប្រការ ១៥.-បំណុលក្រៅសរុប** (Total External Liabilities)

បំណុលក្រៅសរុប (Total External Liabilities) ស្របតាមប្រកាសនេះរួមមាន÷

១-រាល់បំណុលទាំងអស់ស្របតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា។

២-បំណុលជាយថាហេតុទាំងអស់ទោះបីជាបំណុលទាំងនោះមិនត្រូវបានបង្ហាញលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនមូលបត្រក៏ដោយ។

៣-ធាតុផ្សេងទៀតដែលកំណត់ដោយ គ.ម.ក.។

ធាតុមួយចំនួនដែលមិនត្រូវបានរាប់បញ្ចូលជាបំណុលក្រៅសរុបរួមមាន÷

១-បំណុលបំពេញលើដើមទុន (Subordinated Loan) ដែលទទួលបានការអនុញ្ញាត ។

២-សមតុល្យឥណពន្ធ និងសមតុល្យឥណទានដែលមានកិច្ចសន្យាកាត់កងគ្នាស្របច្បាប់អាចត្រូវបានបន្សុតក្នុងការគណនាមូលធនសុទ្ធ។

៣-ធាតុផ្សេងទៀតដែលកំណត់ដោយ គ.ម.ក.។

**ប្រការ ១៦.-បំណុលបំពេញលើដើមទុនដែលអនុញ្ញាត** (Subordinated Loan)

ក្រុមហ៊ុនមូលបត្រអាចដកបំណុលបំពេញលើដើមទុនចេញពីបំណុលក្រៅសរុបបានលុះត្រាតែបានបំពេញលក្ខខណ្ឌដូចខាងក្រោម÷

១-បំណុលបំពេញលើដើមទុននោះត្រូវមានរយៈពេលឥណប្រតិទានយ៉ាងតិច ០២ (ពីរ) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទខ្ចីបំណុល។

២-បរិមាណសរុបនៃបំណុលបំពេញលើដើមទុនទាំងអស់មិនត្រូវលើសពី ៥០ (ហាសិប) ភាគរយនៃមូលធនភាគហ៊ុនិក។

៣-កិច្ចសន្យាបំណុលបំពេញលើដើមទុនត្រូវស្ថិតក្នុងទម្រង់ដែលភ្ជាប់លក្ខខណ្ឌមួយចំនួនដូចខាងក្រោម÷

ក-ឥណទាយកបំណុលបំពេញលើដើមទុនមិនត្រូវទាមទារ ឬទទួលពីក្រុមហ៊ុនមូលបត្រនូវការទូទាត់បំណុលបំពេញលើដើមទុនតាមរយៈការទូទាត់ជាសាច់ប្រាក់ ឬការកាត់កង ឬតាមវិធីសាស្ត្រផ្សេងទៀតរហូតដល់ឥណប្រតិទាន ឬរហូតរាល់ឥណទាយកផ្សេងទៀតទទួលបានការទូទាត់សង លើកលែងតែក្រុមហ៊ុននោះទទួលបានការអនុញ្ញាតជាលាយលក្ខណ៍អក្សរជាមុនពីអគ្គនាយកនៃ គ.ម.ក.។

ខ-ការទាមទារទូទាត់ដោយឥណទាយកបំណុលបំពេញលើដើមទុន ត្រូវស្ថិតនៅលំដាប់រងបន្ទាប់ពីការទាមទារទូទាត់ដោយឥណទាយកបំណុលផ្សេងទៀត។

គ-សិទ្ធិទទួលប្រាក់ដើម និងការប្រាក់ក្នុងអំឡុងពេលខ្ចីបំណុល ត្រូវស្ថិតនៅលំដាប់រងបន្ទាប់ពីឥណទាយកបំណុលផ្សេងទៀត។

ឃ-កាតព្វកិច្ចសងប្រាក់ដើម និងការប្រាក់នៃបំណុលបំពេញលើដើមទុន ត្រូវបានព្យួរក្នុងករណីមូលធនសុទ្ធរបស់ក្រុមហ៊ុនមូលបត្រធ្លាក់ក្រោមកម្រិតមូលធនសុទ្ធកាតព្វកិច្ច។

ង-ក្នុងព្រឹត្តិការណ៍ជម្រះបញ្ជី ឬកែប្រែរចនាសម្ព័ន្ធក្រុមហ៊ុនមូលបត្រ ឥណទាយកបំណុលផ្សេងទៀតត្រូវមានសិទ្ធិទទួលបានការទូទាត់សងទាំងអស់ មុននឹងឥណទាយកបំណុលបំពេញលើដើមទុនអាចទទួលបានការទូទាត់សងចំពោះបំណុលបំពេញលើដើមទុន។

ច-កិច្ចសន្យាបំណុលបំពេញលើដើមទុនមិនត្រូវភ្ជាប់លក្ខខណ្ឌដែលអនុញ្ញាតឱ្យឥណទាយកបំណុលបំពេញលើដើមទុនទាមទារការទូទាត់មុនដល់ឥណប្រតិទាន ឬពន្លឿនការសងបំណុលឡើយ។

ឆ-កិច្ចសន្យាបំណុលបំពេញលើដើមទុនមិនត្រូវភ្ជាប់លក្ខខណ្ឌចាប់បង្ខំសងរួម (Cross Default) ឬលក្ខខណ្ឌហាមឃាត់ការខ្ចីប្រាក់បន្ថែម (Negative Pledge)។

ជ-ការសងបំណុលទាំងអស់ ឬមួយផ្នែកនៃបំណុលបំពេញលើដើមទុន ត្រូវបានធ្វើឡើងតែនៅពេលមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីអគ្គនាយកនៃ គ.ម.ក. ប៉ុណ្ណោះ។

គ.ម.ក. អាចកំណត់ទម្រង់កិច្ចសន្យាបំណុលបំពេញលើដើមទុនផ្សេងពីនេះ។

## ជំពូកទី ៤
## កម្រិតមូលធនសុទ្ធកាតព្វកិច្ច

**ប្រការ ១៧.-កម្រិតមូលធនសុទ្ធកាតព្វកិច្ច** (Prescribed Level of Net Capital) **និងអនុបាតមូលធនសុទ្ធ** (Net Capital Ratio)

កម្រិតមូលធនសុទ្ធកាតព្វកិច្ចរបស់ក្រុមហ៊ុនមូលបត្រគឺជាចំនួនណាមួយដែលខ្ពស់ជាងគេរវាងចំណុចទី ១ និងចំណុចទី ២ ដូចខាងក្រោម÷

១- ៥ (ប្រាំ) ភាគរយនៃមូលធនភាគហ៊ុនិក ។

២- ផលបូកនៃ÷

ក- ១០ (ដប់) ភាគរយនៃបំណុលក្រៅសរុប និង

ខ- ១០ (ដប់) ភាគរយនៃកាតព្វកិច្ចធានាទិញ និង/ឬកាតព្វកិច្ចធានាទិញបន្ត និង/ឬកាតព្វកិច្ចបំណុលលើការធ្វើបរិវិសកម្មរបស់វិនិយោគិនដែលជាអតិថិជនរបស់ក្រុមហ៊ុន។

ក្រុមហ៊ុនមូលបត្រ ត្រូវរក្សាអនុបាតមូលធនសុទ្ធរបស់ខ្លួនមិនឱ្យទាបជាង ១៥០(មួយរយហាសិប) ភាគរយ។

**ប្រការ ១៨.-កាតព្វកិច្ចរៀបចំរបាយការណ៍មូលធនសុទ្ធប្រចាំថ្ងៃ**

ក្រុមហ៊ុនមូលបត្រ ត្រូវគណនាមូលធនសុទ្ធ និងកម្រិតមូលធនសុទ្ធកាតព្វកិច្ចជាប្រចាំថ្ងៃ និងត្រូវផ្ញើជូន គ.ម.ក. ជាប្រចាំថ្ងៃនូវរបាយការណ៍មូលធនសុទ្ធប្រចាំថ្ងៃតាមរយៈសារអេឡិចត្រូនិកដែលកំណត់ដោយ គ.ម.ក.។

**ប្រការ ១៩.-ឆន្ទានុសិទ្ធិកែប្រែកម្រិតមូលធនសុទ្ធកាតព្វកិច្ច**

គ.ម.ក. មានឆន្ទានុសិទ្ធិកែប្រែកម្រិតមូលធនសុទ្ធកាតព្វកិច្ច និងតម្រូវឱ្យក្រុមហ៊ុនមូលបត្របង្កើនមូលធនសុទ្ធ ដោយពិចារណាទៅលើកត្តាមួយចំនួនដូចជា÷

១- ទ្រព្យសកម្មដែលមានលក្ខណៈអសន្ទនីយភាព (Illiquidity) ។

២- ព័ត៌មានហានិភ័យ (Risk profiles) ។

៣- ហានិភ័យផ្សេងៗដែលក្រុមហ៊ុនមូលបត្រអាចជួបប្រទះ។

## ជំពូកទី ៥
## កាតព្វកិច្ចផ្តល់របាយការណ៍ស្ថានភាពមូលធនសុទ្ធ

**ប្រការ ២០.-របាយការណ៍ប្រចាំខែ**

ក្រុមហ៊ុនមូលបត្រត្រូវគណនាមូលធនសុទ្ធ និងកម្រិតមូលធនសុទ្ធកាតព្វកិច្ចព្រមទាំងដាក់ជូនអគ្គនាយកនៃ គ.ម.ក. យ៉ាងយូរត្រឹមថ្ងៃទី ១០ នៃខែបន្ទាប់នូវរបាយការណ៍ប្រចាំខែ ដូចខាងក្រោម÷

១- របាយការណ៍តុល្យភាពសាកល្បងសង្ខេប (Trial Balance in summary) ។

២- របាយការណ៍សន្ទនីយភាព (Liquidity Statement) ។

**ប្រការ ២១.-ឆន្ទានុសិទ្ធិតម្រូវឱ្យគណនា និងធ្វើរបាយការណ៍ស្ថានភាពមូលធនសុទ្ធ**

អគ្គនាយកនៃ គ.ម.ក. អាចតម្រូវឱ្យក្រុមហ៊ុនមូលបត្រធ្វើការគណនា និងធ្វើរបាយការណ៍ស្ថានភាពមូលធនសុទ្ធ និងកម្រិតមូលធនសុទ្ធកាតព្វកិច្ចគ្រប់ពេលវេលាទៅតាមការចាំបាច់។

## ជំពូកទី ៦
## វិធានការកែតម្រូវបន្ទាន់

**ប្រការ ២២.-អនុសាសន៍ពង្រឹងការគ្រប់គ្រង** (Management Improvement Recommendation)

ករណីអនុបាតមូលធនសុទ្ធនៃក្រុមហ៊ុនមូលបត្រធ្លាក់ក្រោម ១៥០ (មួយរយហាសិប) ភាគរយ នៃកម្រិតមូលធនសុទ្ធកាតព្វកិច្ច អគ្គនាយកនៃ គ.ម.ក. ត្រូវផ្តល់អនុសាសន៍ដល់ក្រុមហ៊ុនមូលបត្រនោះឱ្យចាត់វិធានការកែតម្រូវបន្ទាន់។

វិធានការកែតម្រូវបន្ទាន់ដែលចែងក្នុងកថាខណ្ឌទី ១ នៃប្រការនេះ សំដៅលើវិធានការណាមួយ ឬទាំងស្រុងដូចខាងក្រោម÷

១-ពង្រឹងធនធានមនុស្ស និងការគ្រប់គ្រងស្ថាប័ន។

២-កាត់បន្ថយចំណាយ។

៣-ដាក់កម្រិតលើសកម្មភាពនានាដែលនាំឱ្យមានការធ្លាក់ចុះមូលធនសុទ្ធ។

៤-វិធានការចាំបាច់ផ្សេងទៀតតាមការកំណត់របស់អគ្គនាយកនៃ គ.ម.ក.។

**ប្រការ ២៣.-ការតម្រូវពង្រឹងការគ្រប់គ្រង** (Management Improvement Requirement)

ករណីអនុបាតមូលធនសុទ្ធនៃក្រុមហ៊ុនមូលបត្រធ្លាក់ក្រោម ១២០ (មួយរយម្ភៃ) ភាគរយ នៃកម្រិតមូលធនសុទ្ធកាតព្វកិច្ច អគ្គនាយនៃ គ.ម.ក. ត្រូវតម្រូវឱ្យក្រុមហ៊ុនមូលបត្រនោះចាត់វិធានការកែតម្រូវបន្ទាន់។

វិធានការកែតម្រូវបន្ទាន់ដែលចែងក្នុងកថាខណ្ឌទី ១ នៃប្រការនេះសំដៅលើវិធានការណាមួយ ឬទាំងស្រុងដូចខាងក្រោម÷

១-ការដាក់កំហិតលើការកាន់កាប់ទ្រព្យសកម្មដែលមានហានិភ័យខ្ពស់ និងការលក់ ឬដោះដូរទ្រព្យសកម្ម (Disposition of Asset)។

២-ការបិទ និងការបង្រួមបញ្ចូលគ្នា (Consolidation) នូវការិយាល័យអាជីវកម្ម ឬការដាក់កំហិតលើការបើកការិយាល័យអាជីវកម្មថ្មី។

៣-ការទាមទារឱ្យមានការផ្លាស់ប្តូរបុគ្គលិក។

៤-វិធានការដូចមានចែងក្នុងកថាខណ្ឌទី ២ នៃប្រការ ២២ នៃប្រកាសនេះ។

៥-វិធានការចាំបាច់ផ្សេងទៀតតាមការកំណត់របស់អគ្គនាយកនៃ គ.ម.ក.។

**ប្រការ ២៤.-ការបញ្ជាពង្រឹងការគ្រប់គ្រង** (Management Improvement Order)

ករណីអនុបាតមូលធនសុទ្ធនៃក្រុមហ៊ុនមូលបត្រធ្លាក់ក្រោម ១០០ (មួយរយ) ភាគរយ នៃកម្រិតមូលធនសុទ្ធកាតព្វកិច្ច អគ្គនាយកនៃ គ.ម.ក. ត្រូវបញ្ជាឱ្យក្រុមហ៊ុនមូលបត្រនោះចាត់វិធានការកែតម្រូវបន្ទាន់។

វិធានការកែតម្រូវបន្ទាន់ដែលចែងក្នុងកថាខណ្ឌទី ១ នៃប្រការនេះសំដៅលើវិធានការណាមួយ ឬទាំងស្រុងដូចខាងក្រោម÷

១-មិនបង្កើន ឬបន្ថយភ្លាមៗនូវការជួញដូរមូលបត្រ ឬសកម្មភាពហិរញ្ញប្បទាន។

២-ផ្ទេរទាំងអស់ ឬមួយផ្នែកនៃមូលបត្រ វត្ថុបញ្ចាំ ទ្រព្យសកម្ម និងគណនីរបស់អតិថិជនទៅក្រុមហ៊ុនមូលបត្រមួយ ឬច្រើនផ្សេងទៀត។

៣-បន្តប្រតិបត្តិការអាជីវកម្មទៅតាមលក្ខខណ្ឌដែលកំណត់ដោយអគ្គនាយកនៃ គ.ម.ក.។

៤-ផ្អាកជាបណ្ដោះអាសន្ននូវការគ្រប់គ្រងប្រតិបត្តិការអាជីវកម្មដោយអ្នកគ្រប់គ្រង និងតែងតាំងអភិបាលបណ្ដោះអាសន្ន (Administrator)។

៥-វិធានការដូចមានចែងក្នុងកថាខណ្ឌទី ២ នៃប្រការ ២៣ នៃប្រកាសនេះ។

៦-វិធានការចាំបាច់ផ្សេងទៀតតាមការកំណត់របស់អគ្គនាយកនៃ គ.ម.ក.។

## ប្រការ ២៥.-ការផ្ដល់នូវមូលហេតុ

អគ្គនាយកនៃ គ.ម.ក. ត្រូវមានមូលដ្ឋាន និងផ្ដល់នូវមូលហេតុក្នុងការចាត់វិធានការដូចមានចែងក្នុងប្រការ ២២ ប្រការ ២៣ និងប្រការ ២៤ នៃប្រកាសនេះដល់ក្រុមហ៊ុនមូលបត្រដែលទទួលរងវិធានការកែតម្រូវបន្ទាន់។

## ប្រការ ២៦.-ការលើកលែងជាបណ្ដោះអាសន្នចំពោះវិធានការកែតម្រូវបន្ទាន់

ទោះបីជាក្រុមហ៊ុនមូលបត្រស្ថិតក្នុងស្ថានភាពដូចកំណត់ក្នុងកថាខណ្ឌទី ១ នៃប្រការ ២២ កថាខណ្ឌទី ១ នៃប្រការ ២៣ ឬកថាខណ្ឌទី ១ នៃប្រការ ២៤ នៃប្រកាសនេះក៏ដោយ អគ្គនាយកនៃ គ.ម.ក. អាចលើកលែងជាបណ្ដោះអាសន្នចំពោះវិធានការកែតម្រូវបន្ទាន់ក្នុងរយៈពេលជាក់លាក់មួយ ក្នុងករណីក្រុមហ៊ុននោះត្រូវបានវាយតម្លៃថានឹងមិនធ្លាក់ក្នុងស្ថានភាពដែលតម្រូវឱ្យចាត់វិធានការកែតម្រូវបន្ទាន់ ដោយសារការបង្កើនដើមទុន ឬលក់ចេញនូវទ្រព្យសកម្មរបស់ខ្លួនជាដើម។

## ប្រការ ២៧.-ការដាក់ជូន និងការវាយតម្លៃលើផែនការពង្រឹងការគ្រប់គ្រង

ក្រុមហ៊ុនមូលបត្រដែលបានទទួលអនុសាសន៍ ឬការតម្រូវ ឬការបញ្ជាពង្រឹងការគ្រប់គ្រងដូចមានចែងក្នុងប្រការ ២២ ឬប្រការ ២៣ ឬប្រការ ២៤ នៃប្រកាសនេះ ត្រូវរៀបចំផែនការពង្រឹងការគ្រប់គ្រងមួយដែលមានមាតិកាឆ្លុះបញ្ចាំងការពង្រឹងការគ្រប់គ្រងស្របតាមអនុសាសន៍ ឬការតម្រូវ ឬការបញ្ជាដែលទទួលបាន និងដាក់ជូនអគ្គនាយកនៃ គ.ម.ក. ដើម្បីសម្រេចក្នុងរយៈពេល ១ (មួយ) ខែ គិតចាប់ពីកាលបរិច្ឆេទទទួលបានអនុសាសន៍ ឬការតម្រូវ ឬការបញ្ជាឱ្យពង្រឹងការគ្រប់គ្រងនោះ ឬក្នុងរយៈពេលជាក់លាក់មួយកំណត់ដោយអគ្គនាយកនៃ គ.ម.ក.។

អគ្គនាយកនៃ គ.ម.ក. ត្រូវសម្រេចលើផែនការពង្រឹងការគ្រប់គ្រងដែលបានដាក់ជូនដោយក្រុមហ៊ុនមូលបត្រដែលទទួលបានអនុសាសន៍ ឬការតម្រូវ ឬការបញ្ជាពង្រឹងការគ្រប់គ្រងដូចមានចែងក្នុងប្រការ ២២ ឬប្រការ ២៣ ឬប្រការ ២៤ នៃប្រកាសនេះ ក្នុងរយៈពេលយ៉ាងយូរ ១ (មួយ) ខែ គិតចាប់ពីកាលបរិច្ឆេទទទួលបានផែនការពង្រឹងការគ្រប់គ្រងនោះ។

ករណីផែនការពង្រឹងការគ្រប់គ្រងមិនមានលក្ខណៈសមស្របតាមអនុសាសន៍ ឬការតម្រូវ ឬការបញ្ជាពង្រឹងការគ្រប់គ្រង អគ្គនាយកនៃ គ.ម.ក. អាចតម្រូវ ឬបញ្ជាឱ្យក្រុមហ៊ុននោះចាត់វិធានកែតម្រូវបន្ទាន់ដូច

មានចែងក្នុងប្រការ ២៣ ឬប្រការ ២៤ នៃប្រកាសនេះ។ ក្រុមហ៊ុនមូលបត្រត្រូវដាក់ជូនអគ្គនាយកនៃ គ.ម.ក. ឡើងវិញនូវផែនការពង្រឹងការគ្រប់គ្រងក្នុងរយៈពេលជាក់លាក់មួយកំណត់ដោយអគ្គនាយកនៃ គ.ម.ក.។ ករណីក្រុមហ៊ុននៅតែមិនអាចបំពេញតាមការតម្រូវ ឬការបញ្ជា អគ្គនាយកនៃ គ.ម.ក. អាចសម្រេចដាក់ទណ្ឌកម្មរដ្ឋបាលដូចមានចែងក្នុងប្រការ ៣៥ នៃប្រកាសនេះ។

**ប្រការ ២៨.-រយៈពេលអនុវត្តផែនការពង្រឹងការគ្រប់គ្រង**

រយៈពេលអនុវត្តផែនការពង្រឹងការគ្រប់គ្រងត្រូវកំណត់ដូចខាងក្រោម÷

១-រយៈពេល ០៦ (ប្រាំមួយ) ខែ គិតចាប់ពីកាលបរិច្ឆេទសម្រេចលើផែនការពង្រឹងការគ្រប់គ្រងសម្រាប់អនុសាសន៍ពង្រឹងការគ្រប់គ្រង ។

២-រយៈពេល ០១ (មួយ) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទសម្រេចលើផែនការពង្រឹងការគ្រប់គ្រងសម្រាប់ការតម្រូវពង្រឹងការគ្រប់គ្រង។

៣-រយៈពេលអនុវត្តផែនការពង្រឹងការគ្រប់គ្រងសម្រាប់ការបញ្ជាពង្រឹងការគ្រប់គ្រងត្រូវកំណត់ដោយអគ្គនាយកនៃ គ.ម.ក.។

ករណីក្រុមហ៊ុនមូលបត្របានទទួលអនុសាសន៍ពង្រឹងការគ្រប់គ្រងស្របតាមប្រការ ២២ នៃប្រកាសនេះ ហើយក្នុងពេលកំពុងអនុវត្តផែនការពង្រឹងការគ្រប់គ្រង ក្រុមហ៊ុននោះបានទទួលការតម្រូវពង្រឹងការគ្រប់គ្រងបន្ថែមទៀត រយៈពេលអនុវត្តផែនការពង្រឹងការគ្រប់គ្រងមិនត្រូវលើសពី ១ (មួយ) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទសម្រេចលើផែនការពង្រឹងការគ្រប់គ្រងសម្រាប់អនុសាសន៍ដែលទទួលបាន។

**ប្រការ ២៩.-ការស្នើសុំកែប្រែមាតិកាផែនការពង្រឹងការគ្រប់គ្រងដែលបានសម្រេច**

ករណីផែនការពង្រឹងការគ្រប់គ្រងមិនបានសម្រេចតាមគោលដៅគ្រោងទុក ឬមានការលំបាកក្នុងការអនុវត្តតាមផែនការពង្រឹងការគ្រប់គ្រងដោយសារមានការប្រែប្រួលបរិយាកាសអាជីវកម្ម ក្រុមហ៊ុនមូលបត្រអាចស្នើសុំជាលាយលក្ខណ៍អក្សរមកអគ្គនាយកនៃ គ.ម.ក. ដើម្បីកែប្រែមាតិកាផែនការពង្រឹងការគ្រប់គ្រងដោយភ្ជាប់មកជាមួយនូវផែនការពង្រឹងការគ្រប់គ្រងថ្មី។

អគ្គនាយកនៃ គ.ម.ក. ត្រូវជូនដំណឹងអំពីការសម្រេចទទួលយកសំណើកែប្រែមាតិកាផែនការពង្រឹងការគ្រប់គ្រងក្រោយពីវាយតម្លៃទៅតាមករណីនីមួយៗ។ បទប្បញ្ញត្តិចែងក្នុងកថាខណ្ឌទី ៣ នៃប្រការ ២៧ នៃប្រកាសនេះ ត្រូវអនុវត្តដូចគ្នាសម្រាប់ករណីក្រុមហ៊ុនមូលបត្រដែលទទួលបានការយល់ព្រមលើសំណើកែប្រែមាតិកាផែនការពង្រឹងការគ្រប់គ្រងស្របតាមកថាខណ្ឌទី ១ នៃប្រការនេះ។

**ប្រការ ៣០.-របាយការណ៍លទ្ធផលនៃការអនុវត្តផែនការពង្រឹងការគ្រប់គ្រង**

ក្រុមហ៊ុនមូលបត្រដែលបានទទួលការសម្រេចលើផែនការពង្រឹងការគ្រប់គ្រងស្របតាមប្រការ ២៧ នៃប្រកាសនេះ ត្រូវដាក់ជូនអគ្គនាយកនៃ គ.ម.ក. នូវលទ្ធផលអនុវត្តផែនការពង្រឹងការគ្រប់គ្រងប្រចាំត្រីមាសក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ ឬក្នុងរយៈពេលជាក់លាក់មួយកំណត់ដោយអគ្គនាយកនៃ គ.ម.ក. គិតចាប់ពីចុងត្រីមាសនីមួយៗ។

ក្រុមហ៊ុនមូលបត្រដែលបានអនុវត្តផែនការពង្រឹងការគ្រប់គ្រងត្រូវដាក់ជូនអគ្គនាយកនៃ គ.ម.ក. នូវលទ្ធផលអនុវត្តផែនការពង្រឹងការគ្រប់គ្រងក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ ឬក្នុងរយៈពេលជាក់លាក់មួយកំណត់ដោយអគ្គនាយកនៃ គ.ម.ក. បន្ទាប់ពីរយៈពេលនៃការអនុវត្តផែនការនោះបានបញ្ចប់ដូចកំណត់ក្នុងប្រការ ២៨ នៃប្រកាសនេះ។

### ប្រការ ៣១.-ការសម្រេចបញ្ចប់វិធានការកែតម្រូវបន្ទាន់

ក្នុងអំឡុងពេលនៃការអនុវត្តផែនការពង្រឹងការគ្រប់គ្រង ករណីក្រុមហ៊ុនមូលបត្រដែលបានទទួលអនុសាសន៍ ឬការតម្រូវ ឬការបញ្ជាពង្រឹងការគ្រប់គ្រង បានរក្សាអនុបាតមូលធនសុទ្ធលើសពី ១៥០ (មួយរយហាសិប) ភាគរយ នៃកម្រិតមូលធនសុទ្ធកាតព្វកិច្ច អគ្គនាយកនៃ គ.ម.ក. អាចពិចារណាសម្រេចបញ្ចប់វិធានការកែតម្រូវបន្ទាន់។

### ប្រការ ៣២.-វិធានការចំពោះការមិនអនុវត្តតាមផែនការពង្រឹងការគ្រប់គ្រង

ករណីក្រុមហ៊ុនមូលបត្រដែលបានទទួលអនុសាសន៍ ឬការតម្រូវ ឬការបញ្ជាពង្រឹងការគ្រប់គ្រងខកខាន ឬមិនអាចអនុវត្តផ្នែកសំខាន់ៗនៃផែនការពង្រឹងការគ្រប់គ្រង អគ្គនាយកនៃ គ.ម.ក. អាចចាត់វិធានការដូចមានចែងក្នុងកថាខណ្ឌទី ២ នៃប្រការ ២៤ នៃប្រកាសនេះ ឬដាក់ទណ្ឌកម្មរដ្ឋបាលដូចមានចែងក្នុងប្រការ ៣៥ នៃប្រកាសនេះ។

## ជំពូកទី ៧
## ទោសប្បញ្ញត្តិ

### ប្រការ ៣៣.-ការផ្តល់របាយការណ៍យឺតយ៉ាវ

ករណីក្រុមហ៊ុនមូលបត្រមិនគោរពទៅតាមលក្ខខណ្ឌតម្រូវដូចមានចែងក្នុងប្រការ ២០ និង ប្រការ ៣០ នៃប្រកាសនេះ ក្រុមហ៊ុននោះត្រូវទទួលពិន័យអន្តរការណ៍ពី គ.ម.ក. ជាប្រាក់ចំនួន ១.០០០.០០០ (មួយលាន) រៀល ក្នុង ១ (មួយ) ថ្ងៃ ចំពោះការផ្តល់របាយការណ៍យឺតយ៉ាវ។

### ប្រការ ៣៤.-ទណ្ឌកម្មចំពោះការមិនគោរពបទបញ្ញត្តិនៃប្រកាសនេះ

ដោយមិនទាន់គិតពីទោសទណ្ឌផ្សេងទៀតដូចមានចែងក្នុងច្បាប់ និងបទបញ្ញត្តិជាធរមាននៅព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុនមូលបត្រដែលប្រព្រឹត្តិល្មើស ឬខកខានមិនបានអនុវត្តកាតព្វកិច្ចដូចមានចែងក្នុងប្រកាសនេះ ត្រូវទទួលទណ្ឌកម្មរដ្ឋបាលដូចមានចែងក្នុងប្រការ ៣៥ នៃប្រកាសនេះ និង/ឬការផាកពិន័យអន្តរការណ៍ពី គ.ម.ក. ជាប្រាក់ពី ២០.០០០.០០០ (ម្ភៃលាន) រៀល ទៅ ២០០.០០០.០០០ (ពីររយលាន) រៀល ចំពោះនីតិបុគ្គល។

### ប្រការ ៣៥.-ទណ្ឌកម្មរដ្ឋបាល

ក្រុមហ៊ុនមូលបត្រដែលប្រព្រឹត្តល្មើសនឹងបញ្ញត្តិណាមួយនៃប្រកាសនេះ អគ្គនាយកនៃ គ.ម.ក. អាចសម្រេចដាក់ទណ្ឌកម្មរដ្ឋបាលដូចខាងក្រោម÷

១-ការព្រមាន។

២- បទបញ្ជាឱ្យកែតម្រូវ។

៣- ការព្យួរ ឬការបណ្តេញចេញពីមុខតំណែងនូវអភិបាល និង/ឬបុគ្គលិកជាន់ខ្ពស់។

៤- ការដាក់កំហិតលើអាជ្ញាបណ្ណ។

៥- ការព្យួរ ឬការដកហូតអាជ្ញាបណ្ណ។

## ជំពូកទី ៨
## អវសានបញ្ញត្តិ

### ប្រការ ៣៦.-គោលការណ៍ណែនាំផ្សេងៗ

គ.ម.ក. អាចចេញគោលការណ៍ណែនាំដើម្បីសម្រួលការយល់ដឹង និងការអនុវត្តតាមលក្ខខណ្ឌដែលមានចែងក្នុងប្រកាសនេះដល់បុគ្គលពាក់ព័ន្ធ អ្នកចូលរួមក្នុងទីផ្សារមូលបត្រ និងដល់សាធារណជន។

### ប្រការ ៣៧.-បដិវាទកម្ម

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

### ប្រការ ៣៨.-ការអនុវត្ត

អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា នាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ នាយកដ្ឋានកិច្ចការគតិយុត្ត នាយកដ្ឋាន អង្គភាពដទៃទៀតចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា ក្រុមហ៊ុនមូលបត្រ និងបុគ្គលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ២០១២

**គាត ឈន់**

**ចម្លងជូន÷**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
- នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- ធនាគារជាតិនៃកម្ពុជា
- គណៈកម្មការមូលបត្រកម្ពុជា
- គ្រប់ក្រសួង និងស្ថាប័នពាក់ព័ន្ធ

  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៣៨

  "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ